ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ
លេខ ០៤៩ សជវវ /គ.ជ.វ.វ

19.02.07

# សេចក្ដីសម្រេច
## ស្ដីពី
## តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ក្រុមការងារ នៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

## គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៥៥ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០០៦ ស្ដីពីការបង្កើតក្រុមការងាររបស់ គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- យោងតាមស្មារតីនៃអង្គប្រជុំរបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នាថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៦ ។

## សម្រេច

**ប្រការ១ .-**

ក្រុមការងារនៃ គ.ជ.វ.វ មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម ៖

- ធ្វើជាជំនួយការ និងផ្ដល់យោបល់ដល់ គ.ជ.វ.វ និងអនុគណៈកម្មការនានារបស់ គ.ជ.វ.វ
- លើកសំណើជូន គ.ជ.វ.វ អំពីការរៀបចំបង្កើតអនុគណៈកម្មការនានារបស់ គ.ជ.វ.វ តាមការចាំបាច់ ព្រមទាំងសមាសភាព មុខងារ និងនីតិវិធីការងារសម្រាប់អនុគណៈកម្មការទាំងនេះ
- រៀបចំសេចក្ដីព្រាងគោលការណ៍ណែនាំ និងឯកសារដទៃទៀត រួមទាំងសេចក្ដីព្រាងផែនការ និងថវិកា ដើម្បីដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេច

- ត្រួតពិនិត្យ និងធានាការអនុវត្តសេចក្តីសម្រេចរបស់ គ.ជ.វ.វ ឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា

- ត្រួតពិនិត្យ និងចាត់ចែងសកម្មភាពរបស់ គ.ជ.វ.វ តាមការសម្រេចរបស់ គ.ជ.វ.វ នៅចន្លោះការប្រជុំរបស់ គ.ជ.វ.វ

- ផ្តល់របាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនឱ្យបានទៀងទាត់ជូន គ.ជ.វ.វ និង

- បំពេញកិច្ចការទាំងអស់ដែលចាំបាច់ ដើម្បីធានាដល់ការប្រព្រឹត្តិទៅរបស់ គ.ជ.វ.វ ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ។

**ប្រការ២ .-**

ក្រុមការងារត្រូវទទួលខុសត្រូវ លើកិច្ចការជាអាទិភាព ដូចខាងក្រោម ÷

- ត្រូវដាក់ជូន គ.ជ.វ.វ ពិនិត្យ សម្រេចអំពីនីតិវិធី និងរបៀបរបបការងាររបស់ គ.ជ.វ.វ

- ដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចលើសេចក្តីព្រាងក្របខ័ណ្ឌអនុវត្តបឋម ដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- ដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចលើសេចក្តីព្រាងល័ក្ខខ័ណ្ឌការងារសម្រាប់ការរៀបចំតាក់តែងកម្មវិធីជាតិបឋម ដើម្បីការអភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- ត្រូវរៀបចំ និងដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចលើសេចក្តីព្រាងផែនការការងាររបស់ គ.ជ.វ.វ និងថវិកាសម្រាប់ឆ្លើយតបផែនការការងារនោះ សម្រាប់រយៈពេលនៅសល់នៃឆ្នាំ ២០០៦ និងឆ្នាំ ២០០៧

- ផ្តល់អនុសាសន៍ជូន គ.ជ.វ.វ អំពីការបង្កើតអនុគណៈកម្មការនានារបស់ គ.ជ.វ.វ តាមការចាំបាច់ ។

**ប្រការ៣ .-**

ក្រុមការងារត្រូវជួយ គ.ជ.វ.វ ក្នុងការអនុវត្តនូវកិច្ចការដែលនៅសេសសល់របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងគណៈកម្មការអន្តរក្រសួងដើម្បីតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ

ក្រុមការងារត្រូវប្រើប្រាស់មធ្យោបាយ និងដំណើរការចាំបាច់នានាដើម្បីធានាឱ្យគ.ជ.វ.វទទួល និងអនុវត្តមុខងារ និងភារកិច្ចខាងលើនេះឱ្យបានត្រឹមត្រូវ ។

**ប្រការ៤ .-**

ក្រុមការងារត្រូវចាត់ចែងអនុវត្តនូវផ្នែកទាំងអស់នៃក្របខ័ណ្ឌអនុវត្តបឋមដែលបានអនុម័ត ។

**ប្រការ៥ .-**

ក្នុងការរៀបចំកម្មវិធីជាតិបឋម ក្រុមការងារត្រូវចាត់ចែងការងារ ដូចខាងក្រោម ៖

- ស្នើរៀបចំឱ្យមានសមាជិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាល សមាជិកអន្តរជាតិ និងសមាជិកដទៃទៀតនៅក្នុងក្រុមរៀបចំបង្កើតកម្មវិធីជាតិជាបឋម

- ផ្តល់គោលការណ៍ណែនាំ ដឹកនាំ និងគាំទ្រដល់ក្រុមរៀបចំបង្កើតកម្មវិធីជាតិ

- ចាត់ចែងអនុវត្តផ្នែកទាំងអស់នៃកម្មវិធីជាតិបឋមដែលបានអនុម័ត ។

**ប្រការ៦ .-**

ក្នុងការរៀបចំមូលនិធិសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ ក្រុមការងារត្រូវ ៖

- ដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចអំពីមូលនិធិពីដៃគូអភិវឌ្ឍន៍ សម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលបានស្នើសម្រាប់ដៃគូអភិវឌ្ឍន៍ ដែលមានបំណងប្រមូលធនធានរបស់ខ្លួន ដើម្បីគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ទៅលើខ្លឹមសារ និងដំណើរការនៃមូលនិធិវិមជ្ឈការ និងវិសហមជ្ឈការ

- ក្រុមការងារត្រូវផ្តល់អនុសាសន៍ជូន គ.ជ.វ.វ ពីគោលនយោបាយ និងវិធីដ៏ប្រសើរបំផុតសម្រាប់ការចាត់ចែងមូលនិធិវិមជ្ឈការ និងវិសហមជ្ឈការ

- នៅក្នុងអនុសាសន៍របស់ខ្លួន ក្រុមការងារត្រូវដាក់បញ្ចូលនូវការវាយតម្លៃអំពីតម្រូវការ និងការចង់ឱ្យមាននូវកិច្ចសន្យាជាមួយអ្នកចាត់ចែងមូលនិធិ រហូតដល់ពេលអាជ្ញាធរអនុវត្តន៍ដែលបង្កើតឡើងដោយច្បាប់រៀបចំអង្គការ ឬទីភ្នាក់ងារសមស្របមួយរបស់រាជរដ្ឋាភិបាលដែលមានសមត្ថភាពចាត់ចែងមូលនិធិទាំងនោះ ។

**ប្រការ៧ .-**

ក្នុងការប្រមែប្រមូលមូលនិធិនានា សម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ ក្រុមការងារត្រូវ ៖

- ដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចអំពីជម្រើស យន្តការ ទីភ្នាក់ងារ និងការចាត់ចែងដ៏ប្រសើរបំផុតដើម្បីកៀរគរ និងចាត់ចែងមូលនិធិអន្តរជាតិសម្រាប់ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- ត្រូវដាក់បញ្ចូលទៅក្នុងអនុសាសន៍របស់ខ្លួននូវ ជម្រើសយន្តការ ទីភ្នាក់ងារ និងការចាត់ចែងដ៏ប្រសើរបំផុតនៅមុន និងក្រោយការអនុម័តច្បាប់រៀបចំអង្គការ

- ត្រូវពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍នានាអំពីជម្រើស យន្តការ ទីភ្នាក់ងារ និងការចាត់ចែងដ៏ប្រសើរបំផុតនូវមូលនិធិរបស់ដៃគូអភិវឌ្ឍន៍

**ប្រការ៨ .-**

ក្នុងការរៀបចំ សម្រាប់ដំណាក់កាលអន្តរកាល និងការរំសាយកម្មវិធីសិលាជាបណ្តើរៗ ក្រុមការងារត្រូវ ÷

- ដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចពីយុទ្ធសាស្ត្រ និងដំណើរការដ៏សមស្រប សម្រាប់ដំណាក់កាលអន្តរកាល និងដំណាក់កាលរំសាយកម្មវិធីសិលាជាបណ្តើរៗ

- កំណត់អំពីមុខងារ និងការទទួលខុសត្រូវរបស់ក្រុមការងារកម្មវិធីសិលា និងលេខាធិការដ្ឋានកម្មវិធីសិលា ដែលផ្ទេរទៅឱ្យ គ.ជ.វ.វ ក្រុមការងារនៃគ.ជ.វ.វ ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័ននានា ឬទីភ្នាក់ងារជាតិ ឬទីភ្នាក់ងារនៅថ្នាក់ក្រោមជាតិនានា

- ធានាចំពោះការអនុវត្តយុទ្ធសាស្ត្រ និងដំណើរការដែលបានសម្រេចសម្រាប់ដំណាក់កាលអន្តរកាល និងដំណាក់កាលរំសាយកម្មវិធីសិលាជាបណ្តើរៗ ។

**ប្រការ៩ .-**

ក្រុមការងារត្រូវដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចលើសេចក្តីព្រាងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ស្តីពីការគាំទ្រវិមជ្ឈការ និងវិសហមជ្ឈការ ។

**ប្រការ១០ .-**

ក្រុមការងារត្រូវធានាឱ្យមានកិច្ចសហប្រតិបត្តិការ និងការពិគ្រោះយោបល់នៅក្នុងចំណោមអ្នកពាក់ព័ន្ធនានា រួមមាន ÷

- ផ្តល់អនុសាសន៍ជូន គ.ជ.វ.វ អំពីការរៀបចំចាត់ចែងដ៏សមស្រប សម្រាប់ការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់រៀបចំអង្គការ និងក្របខ័ណ្ឌអនុវត្តបឋម

- សម្របសម្រួល និងធានាឱ្យមានការពិគ្រោះយោបល់ឱ្យបានគ្រប់គ្រាន់ ក្នុងចំណោមក្រសួង ស្ថាប័ននានា នៃរាជរដ្ឋាភិបាល ស្ថាប័នថ្នាក់ជាតិដទៃទៀត និងទីភ្នាក់ងាររាជរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ ទាក់ទិនទៅនឹងការជ្រើសរើស ការផ្ទេរមុខងារ និងធនធានទៅឱ្យក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ

- គ.ជ.វ.វ ត្រូវធានាឱ្យមានកិច្ចសហប្រតិបត្តិការ និងការពិគ្រោះយោបល់ដ៏សមស្រប និងគ្រប់គ្រាន់ រវាង គ.ជ.វ.វ ក្រសួង ស្ថាប័ន ទីភ្នាក់ងារនៅថ្នាក់ជាតិ និងទីភ្នាក់ងារនៅថ្នាក់ក្រោមជាតិ ។

**ប្រការ១១ .-**

ក្រុមការងារត្រូវធានាឱ្យមានវេទិកាសមស្របរវាងរាជរដ្ឋាភិបាល ទីភ្នាក់ងារអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាល ដែលរួមមាន ÷

- ផ្តល់អនុសាសន៍ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចនូវការរៀបចំវេទិកាដ៏សមស្រប សម្រាប់ការពិគ្រោះយោបល់ ទំនាក់ទំនងកិច្ចសហប្រតិបត្តិការ និងការកៀរគរមូលនិធិរវាងរាជរដ្ឋាភិបាល ទីភ្នាក់ងារអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាល

- សម្របសម្រួល និងធានាឱ្យមានការប្រជុំសម្រាប់កិច្ចសហប្រតិបត្តិការរវាង គ.ជ.វ.វ ទីភ្នាក់ងារអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាលតាមការចាំបាច់

- ផ្តល់អនុសាសន៍ជូន គ.ជ.វ.វ និងចាត់វិធានការ ដើម្បីធានាឱ្យបានថា សកម្មភាព និងកម្មវិធីរបស់ទីភ្នាក់ងារអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាលនានា ស្របគ្នា និងស៊ីសង្វាក់គ្នាជាមួយក្របខ័ណ្ឌអនុវត្តបឋម និងកម្មវិធីជាតិបឋម ។

**ប្រការ១២ .-**

ដើម្បីធ្វើជាជំនួយការឱ្យ គ.ជ.វ.វអនុវត្តមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព ក្រុមការងារមានសិទ្ធិ អំណាចដូចខាងក្រោម ÷

- អាចជួបប្រជុំជាមួយទីភ្នាក់ងារអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាលសម្រាប់ការពិគ្រោះយោបល់ ការផ្សព្វផ្សាយព័ត៌មាន ឬសម្រាប់គោលបំណងដទៃទៀតដែលស្ថិតនៅក្នុងការទទួលខុសត្រូវរបស់ គ.ជ.វ.វ

- រៀបចំសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ ឬអនុក្រឹត្យដើម្បីដាក់ជូន គ.ជ.វ.វ ពិនិត្យ និងជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងសម្រេច

- អាចស្នើសុំឱ្យក្រសួង ឬស្ថាប័នជាតិ ផ្តល់ព័ត៌មានដែលពាក់ព័ន្ធទៅនឹងការអនុវត្តកម្មវិធីជាតិបឋម នៅក្នុងរយៈពេលកំណត់ជាក់លាក់មួយ

- អាចទទួលជំនួយបច្ចេកទេស ហិរញ្ញវត្ថុ និងសម្ភារពីប្រភពក្នុងប្រទេស និងក្រៅប្រទេស សម្រាប់គាំទ្រដល់ការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ

- អាចជួលទីប្រឹក្សាជំនាញ ជាជនជាតិកម្ពុជា និងបរទេស តាមការចាំបាច់

-អាចចុះកិច្ចសន្យា រួមទាំងកិច្ចសន្យាទទួលជំនួយហិរញ្ញវត្ថុពីប្រភពក្នុងប្រទេស និងក្រៅប្រទេស និងកិច្ចសន្យាជួលទីប្រឹក្សាជំនាញ ស្របទៅតាមនីតិវិធីដែលបានកំណត់ ។

**ប្រការ១៣ .-**

ក្រុមការងារត្រូវជួបប្រជុំយ៉ាងហោចណាស់មួយខែម្តង

ក្រុមការងារអាចអញ្ជើញតំណាងក្រសួងផ្សេងៗទៀត ឬបុគ្គលទាំងឡាយឱ្យចូលរួមនៅក្នុងការប្រជុំរបស់ខ្លួនតាមការចាំបាច់ ។

**ប្រការ១៤ .-**

ក្រុមការងារត្រូវរាយការណ៍ពីសកម្មភាពរបស់ខ្លួន នៅគ្រប់អង្គប្រជុំរបស់ គ.ជ.វ.វ ។

**ប្រការ១៥ .-**

ក្រុមការងារត្រូវផ្តល់គោលការណ៍ណែនាំ និងការដឹកនាំដល់លេខាធិការដ្ឋាន គ.ជ.វ.វ

ក្រុមការងារអាចស្នើសុំជំនួយពីលេខាធិការដ្ឋាន គ.ជ.វ.វ សម្រាប់បញ្ហាទាំងឡាយណាដែលឋិតនៅក្នុងវិសាលភាពនៃភារកិច្ច និងអំណាចរបស់ខ្លួន ។

**ប្រការ១៦ .-**

សមាជិកគ្រប់រូបនៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមការងារ លេខាធិការដ្ឋាន និងមន្ត្រីពាក់ព័ន្ធនានា ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ,* ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០០៧

**ជ.គណៈកម្មាធិការជាតិដឹកនាំការងារ**
**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**
**ប្រធាន**

**ស ខេង**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល
- សមាជិក គ.ជ.វ.វ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ